ក្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ៦៩ ចេញផ្សាយថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣
No. 69 Released on March 8, 2023

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# ការបង្កើតស្ថេរភាពហិរញ្ញវត្ថុគ្រួសារឆ្លងជំនាន់តាមរយៈការបង្កើតបរធនបាលកិច្ច

## Establishing Financial Stability for the Next Generation of Families through the Establishment of Trust




https://smartwills.ca/insurance-trust/

បរធនបាលកិច្ចធានារ៉ាប់រង ជាប្រភេទបរធនបាលកិច្ចដែលត្រូវបានបង្កើតឡើងដោយបរធនបាលទាយក ដែលធម្មតាជាមេគ្រួសារ ដោយមុនដំបូងបានទិញគម្រោងធានារ៉ាប់រងអាយុជីវិត, គម្រោងអនាគតការសិក្សារបស់កូន ឬគម្រោងណាមួយផ្សេងៗទៀតទៅឱ្យសមាជិកណាមួយក្នុងគ្រួសារ បន្ទាប់មកតាមរយៈធានារ៉ាប់រងដែលបានទិញ រាល់សំណងទូទាត់ដែលទទួលបានពីធានារ៉ាប់រងដែលបានទិញ ត្រូវបានផ្ទេរទៅក្នុងបរធនបាលកិច្ចដែលជាយន្តការការពារសុវត្ថិភាព និងផ្តល់សេចក្តីស្រឡាញ់មួយកម្រិតថែមទៀត។

បរធនបាលកិច្ចប្រភេទនេះ អាចជួយធានា ថែរក្សា និងការពារអនាគតហិរញ្ញវត្ថុដ៏រឹងមាំរបស់ក្រុមគ្រួសារ ប្រកបដោយនិរន្តភាព និងភាពត្រឹមត្រូវច្បាស់លាស់ នៅពេលដែលអវត្តមាននៃមេគ្រួសារនោះ ឬក្នុងករណីដូចជាមានហេតុការណ៍អកុសលណាមួយកើតឡើង (មរណភាព ឬពិការភាពទាំងស្រុងរបស់មេគ្រួសារ)។

លើសពីការជួយជំរុញ និងធានានិរន្តរភាពភាពហិរញ្ញវត្ថុគ្រួសារឆ្លងជំនាន់ បរធនបាលកិច្ចធានារ៉ាប់រងក៏ជាឧបករណ៍សម្រាប់ការពារហានិភ័យមួយចំនួន និងផ្តល់ការយកចិត្តទុកដាក់ និងក្តីស្រឡាញ់ដល់អ្នកជំនាន់ក្រោយផងដែរ។

Insurance Trust is a type of trust created by a trustor who is usually the head of the family by first purchasing a life insurance plan, a child's future education plan, or any other plan to a member of the family. The family then, through the purchase of insurance, all the compensation received from the purchase of insurance is transferred to the trust, which is a mechanism of protection, security and provide another level of love.

This type of trust can help ensure the protection of a strong financial future of the family in a sustainable and accurate manner in the absence of the head of the household or in the event of an unfortunate incident (death or disability).

In addition to helping to promote and ensure the financial sustainability of the families, insurance trust is also a tool to prevent some risks and provide care and love for the next generation.

**អត្ថបទ÷ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References:**

- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) និងបទប្បញ្ញត្តិពាក់ព័ន្ធ
- https://www.investopedia.com/terms/i/insurance_trust.asp
- https://trustandwill.com/learn/insurance-trust

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.